# កំណើនពន្ធ នៃកម្មវិធីឯកភាពរបាយការណ៍ជាអេឡិកត្រូនិក

<u>តើរបាយការណ៍ជាអេឡិកត្រូននិក ជាអ្វី?</u>

ច្បាប់ថ្មីបានចាប់ប្រតិបត្តិនៅឆ្នាំ 2008 ដែលនឹងតម្រូវឲ្យក្រុមហ៊ុនទាំងអស់ នៅក្រោមអាណត្តិ ព្រមទាំងភ្នាក់ងាររដ្ឋាភិបាលតាមតំបន់ទាំងអស់ នៅក្រោមអាណត្តិ ដែលហៅថា ភ្នាក់ងារកម្មវិធីឯកភាព (Unified Program Agencies [UPA]) ឲ្យប្រើអ៊ិនទ័រណិត ដើម្បីបំពេញព័ត៏មានកម្មវិធី ឯកភាពដែលបានតម្រូវ ដែលនៅពេលឥឡូវនេះបំពេញដោយទំរង់ក្រដាស ។ នេះរួមមានបញ្ជិត្តិសកម្មភាពទិន្នន័យស្ថាប័ន ស្តីពីសំភារៈដែលគ្រោះថ្នាក់ សារពើភណ្ឌជាតិគីមី ធុងផ្ទុកសំភារៈនៅក្រោមដីនិងនៅខាងលើដី ការបង្កើតឲ្យមានសំណល់ដែលគ្រោះថ្នាក់ ។ វាក៏រួមមានទិន្នន័យ UPA ដូចជាការ ត្រួតពិនិត្យ និងការបង្ខំឲ្យប្រតិបត្តិផងដែរ ។

<u>តើក្រុមហ៊ុនត្រូវបំពេញជាអេឡិកត្រូនិក នៅពេលណា?</u>

ក្រុមហ៊ុនទាំងអស់នៅក្រោមអាណត្តិ និង UPA នៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ា ត្រូវតែប្រើអ៊ិនទ័រណិត ដើម្បីបំពេញរបាយការណ៍ នៅថ្ងៃទី 1 ខែមករា ឆ្នាំ 2013 ។ អ្នកបំពេញជាអេឡិកត្រូនិកដំបូងគេបំផុត នឹងចាប់ផ្តើមប្រើប្រពន្ធទូទាំងរដ្ឋ ដែលហៅថា ប្រព័ន្ធរបាយការណ៍បរិស្ថានរដ្ឋកាលីហ្វ័រនីញ៉ា (California Environmental Reporting System [CERS]) នៅក្នុងខែកញ្ញា ឆ្នាំ 2009 ។ ដោយយោងទៅលើពេលវេលាដែល UPA របស់អ្នក អាចទទួលទិន្នន័យពីប្រព័ន្ធរដ្ឋ នោះវានឹងអនុម័តអំពីពេលវេលានៃរបាយការណ៍ជាអេឡិកត្រូនិក ដែលត្រូវធ្វើជាដាច់ខាតនៅតាមតំបន់ ហើយការបំពេញជាក្រដាស នឹងលែងជាការជ្រើសរើសទៀតហើយ ។ បន្ទាប់ពីមាន CERS មក ក្រុមហ៊ុនទាំងពួងអាចស្ម័គ្រចិត្តប្រើវា ដើម្បីបញ្ចូល និងរក្សាទុកការបំពេញព័ត៏មានរបស់គេបាន ប៉ុន្តែអាចនឹងនៅតែត្រូវផ្តិតក្រដាសបំពេញ ចេញពី CERS ដើម្បីបំពេញជាមួយនឹង UPA របស់គេ ។ បើសិនជាភ្នាក់ងារ UPA នៅតាមតំបន់របស់អ្នក មិនទាន់បានទាក់ទងអ្នក ជាប់ទាក់ទងព័ត៏មានស្តីការប្រើ CERS នៅឡើយទេ យើងសូមឲ្យយោបល់ថាក្រុមហ៊ុនទាំងនោះ ទាក់ទងទៅ UPA នៅក្នុងតំបន់របស់គេ សំរាប់ព័ត៏មានបន្ថែម ។

<u>តើកំណើនពន្ធ នៃរបាយការណ៍ជាអេឡិកត្រូនិកជាអ្វី ហើយនៅឥឡូវនេះវាមានតម្លៃប៉ុន្មាន?</u>

ក្រុមហ៊ុនទាំងអស់ដែលនៅក្រោមអាណត្តិ ឥឡូវនេះបង់កំណើនពន្ធរដ្ឋយ៉ាងតិចបំផុត $24 សំរាប់ UPA របស់គេ ។ ដើម្បីបង់ថ្លៃការប្រតិបត្តិនៃរបាយការណ៍ជាអេឡិកត្រូនិកទូទាំងរដ្ឋ នោះអង្គនីតិបញ្ញត្តិ(កន្លែងបង្កើតច្បាប់) កំពុងតែបង្កើតកំណើនពន្ធជាបណ្តោះអាសន្ន ដោយបង្កើនតម្លៃ $25 ក្នុងមួយឆ្នាំ ចំនួនបីឆ្នាំ ។ ប្រាក់បន្ថែមនេះនឹងបានប្រើសំរាប់ការបង្កបង្កើតប្រព័ន្ធ ការផ្សព្វផ្សាយ និងការហ្វឹកហ្វឺន ព្រមទាំងការគាំទ្របច្ចេកទេស សំរាប់ UPA ដើម្បី ឲ្យអាចទទួលព័ត៏មានជាអេឡិកត្រូនិកបាន ។ នេះមានសេចក្តីថា ចំនួនយ៉ាងតិចបំផុតនៃកំណើនពន្ធរដ្ឋដែលអ្នកត្រូវបង់ នឹងកើនពី $24 ក្នុងមួយឆ្នាំ ទៅជា $49 ក្នុងមួយឆ្នាំ ។ ភ្នាក់ងារកម្មវិធីឯកភាពបានបញ្ជាក់ (Certified Unified Program Agencies [CUPA]) របស់អ្នក នឹងបន្ថែមកំណើន ពន្ធនៃរបាយការណ៍ជាអេឡិកត្រូនិក ទៅលើរបាយការណ៍វិក្កយបត្រប្រចាំឆ្នាំរបស់អ្នក ចំនួនបីដងបន្ទាប់ទៀតនេះ ។ អ្នកនឹងនៅតែត្រូវ បង់កំណើនពន្ធ រដ្ឋ ទៅឲ្យ UPA របស់អ្នក បន្ថែមលើថ្លៃឈ្នួលនៃ UPA នៅក្នុងតំបន់របស់អ្នក ។

<u>តើរបាយការណ៍ជាអេឡិកត្រូនិក នឹងជួយក្រុមហ៊ុន ដោយរបៀបណា?</u>

ការរាយការណ៍ជាអេឡិកត្រូនិកទូទាំងរដ្ឋ ដែលបំពេញតាមរយៈអ៊ិនទ័រណិត នឹងអនុញ្ញាតឲ្យ :

- ក្រុមហ៊ុនដែលនៅក្រោមអាណត្តិ នឹងងាយស្រួលអាចរក្សា និងកែឲ្យទាន់សភាពការណ៍ នូវព័ត៏មានជាបញ្ជិត្តិរបស់គេ ។
- អ្នកប្រឹក្សាខាងបរិស្ថាន នឹងអាចបំពេញជាអេឡិកត្រូនិក សំរាប់ក្រុមហ៊ុន ។
- ក្រុមហ៊ុនដែលមាននៅច្រើនកន្លែង នឹងអាចបំពេញតែមួយកន្លែង តាមរយៈ CERS ។
- ក្រុមហ៊ុននឹងចំណេញពេលវេលា ដោយមិនបាច់ធ្វើ និងមិនបាច់បញ្ចូលម្តងទៀត នូវទិន្នន័យដែលមាននៅក្នុង CERS ស្រាប់ហើយ ។
- ក្រុមហ៊ុនអាចំណេញកន្លែងសំរាប់ទុកដាក់ក្រដាស ពីព្រោះវាឋិតនៅក្នុងកន្លែងមួយ ជាសំណុំរឿងអេឡិកត្រូនិកអាចមើលបាន ។
- ភ្នាក់ងារតបឆ្លើយ អាចមើលព័ត៏មាននៅពេលណាក៏បាន សំចៃក្រុមហ៊ុនអំពីការបំពេញតាមសេចក្តីតម្រូវជាដដែលៗ ។

<u>តើក្រុមហ៊ុនចាប់ផ្តើម ដោយរបៀបណា?</u>

ជាដំបូង ត្រូវពិគ្រោះជាមួយនឹង UPA នៅក្នុងតំបន់របស់អ្នក ។ គេនឹងមានព័ត៏មានថែមទៀត ស្តីអំពីពេលវេលា និងសេចក្តីតម្រូវនៅតាមតំបន់ ។ UPA ក៏នឹងផ្តល់ព័ត៏មាន តាមរយៈកម្មវិធីផ្សព្វផ្សាយទៅក្រុមហ៊ុន នៅក្នុងតំបន់របស់គេ នៅពេលដែលរបាយការណ៍ជាអេឡិកត្រូនិកត្រូវបានប្រតិបត្តិនៅសព្វទូទាំងរដ្ឋ ។ ទំព័រជំនួយ មានសេចក្តីក្បោះក្បាយ ការណែនាំ និងការបង្រៀនតាមអ៊ិនទ័រណិត ក៏បានកសាងឡើងចូលក្នុង CERS នៅដើមឆ្នាំ 2010 ។ នៅទីបំផុត ព័ត៏មានស្តីពីសេចក្តីតម្រូវរបាយការណ៍ជាអេឡិកត្រូនិក កំពុងតែបានបង្កើតឡើងដោយ ភ្នាក់ងារការពារបរិស្ថានរដ្ឋកាលីហ្វ័រនីញ៉ា (California Environmental Protection Agency [CalEPA]) ហើយនឹងបានបិទប្រកាសនៅទំព័ររបាយការណ៍ជាអេឡិកត្រូនិក (Electronic Reporting) នៅឯ [www.calepa.ca.gov/CUPA](http://www.calepa.ca.gov/CUPA) ។ អ្នកគួរតែឆែកមើលវ៉ិបសៃត៍ UPA នៅ ក្នុងតំបន់របស់អ្នក និងវ៉ិបសៃត៍នេះ សំរាប់ព័ត៏មានបន្ថែម ។

ព័ត៏មាននៅក្នុងខិត្តប័ណ្ណនេះ មានជាភាសាដូចជាលំដាប់នេះ នៅលើវ៉ិបសៃត៍របស់ CalEPA : អេស្ប៉ាញ៉ុល, អារ៉ាប់, ហិនឌី, អ័រឌូ, ហ្វាស៊ី, រុស្ស៊ី, ចិន, កូរេ, តាហ្គាឡុក, ថៃ, និង លាវ ។